ក្រសួងអប់រំ យុវជន និង កីឡា

# ១១ ប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មាន

## បញ្ឈប់ពលកម្មកុមារ

### ការពារសិទ្ធិកុមារតាមរយៈការអប់រំ_សិល្បៈ និងប្រព័ន្ធផ្សព្វផ្សាយ

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ

អង្គការពលកម្មអន្តរជាតិ

២០០៧

## វត្ថុបំណង :

ដើម្បីអភិវឌ្ឍន៍ទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយក្នុងការទាក់ទាញចំណាប់អារម្មណ៍សាធារណៈជន ឱ្យផ្តោតទៅលើការងារពលកម្មកុមារ ។ ពន្យល់អំពីការងារប្រព័ន្ធផ្សព្វផ្សាយ ហ្វឹកហាត់និពន្ធអត្ថបទសារព័ត៌មានខ្លីៗ ដើម្បីផ្សព្វផ្សាយ ។





**លទ្ធផលរំពឹងទុក :** លើកកំពស់សមត្ថភាពចំណេះដឹងឱ្យបានខ្លាំងក្លា និងសំបូរបែបសម្រាប់សហគមន៍

## ការកំណត់ពេលវេលា

បង្រៀនម្តង ២ពេលជាប់គ្នា ឬដាច់ពីគ្នា

## ហេតុផល

គឺមានតែប្រព័ន្ធផ្សព្វផ្សាយទេ ដែលជាគន្លឹះសម្រាប់បញ្ចុះបញ្ចូលសហគមន៍ឱ្យចូលរួមយុទ្ធនាការលុបបំបាត់ពលកម្មកុមារ ។ នៅក្នុងសករាជនៃសាកលលោកនេះ កិច្ចទំនាក់ទំនង និងព័ត៌មានដែលកើតឡើងថ្មីៗ មានសារៈសំខាន់ណាស់ សម្រាប់ឱ្យសហគមន៍យល់ដឹងអំពីពលកម្មកុមារ ។



យើងបានបញ្ចូលមេរៀនចំនួន ២ ស្តីពីប្រព័ន្ធផ្សព្វផ្សាយ ។ មេរៀនទីមួយបកស្រាយពីរបៀបអត្ថបទ (កាសែត ឧទាហរណ៍ ការសរសេរអត្ថបទកាសែត និងអត្ថបទចុះ និងទស្សនាវដ្តី ។ មេរៀនមួយទៀតផ្តោតទៅលើការផ្សាយតាមវិទ្យុ និងទូរទស្សន៍ ។ មេរៀនទាំងពីរនេះសំដៅចំពោះប្រជាជនជាយុវជនអាចចូលរួមផ្សព្វផ្សាយព័ត៌មាន ក្នុងគំរោងរបស់ពួកគេនឹងធ្វើឱ្យប្រជាជននៅក្នុងសហគមន៍យល់អំពីអ្វីដែលពួកគាត់កំពុងធ្វើ និងធ្វើដូចម្តេចឱ្យសហគមន៍អាចជួយពួកគេបាន ។ អត្ថប្រយោជន៍ដ៏សំខាន់របស់មេរៀនទាំងពីរនេះគឺថាវាជួយជំរុញពួកក្មេងៗឈានទៅរកការអនុវត្តជំនាញ និងសមត្ថភាព



## កំណត់សម្គាល់
## សម្រាប់អ្នកប្រើប្រាស់

នេះ គឺជាគំនិតល្អមួយសម្រាប់អ្នកអនុវត្តស្រាវជ្រាវមេរៀនព័ត៌មានដែលពុំបានដឹងមុនចំពោះវគ្គសិក្សាមេរៀននេះ។ លំហាត់ដែលបានដកស្រង់ពីក្នុងទំព័រកាសែតសមាជិកក្រុមបានវិភាគអំពីពលកម្មកុមារពាក់ព័ន្ធនឹងសិទ្ធមនុស្សដែលពួកគេបានដកស្រង់ចេញពីមាត្រាខ្លះនៃអត្ថបទសារព័ត៌មាន និងទស្ស-នាវដ្ដី ដោយផ្អែកលើការវិភាគអត្ថបទដកស្រង់ព័ត៌មានទាំងនេះ ក្រុមសិស្សនឹងយល់ដឹងបានល្អប្រសើរ ពីអ្វីដែលជាចំណងជើងគួរជាទីចាប់អារម្មណ៍នូវប្រយោគផ្ដើមងាយយល់ដឹងសាច់រឿងសំខាន់ៗ។ល។ ដោយសារការវិភាគនេះនឹងជួយពួកគេឱ្យចេះបំពេញលំហាត់ក្នុងមេរៀនបានល្អប្រសើរ។

ដែលពួកគេបាន និង កំពុងអភិវឌ្ឍរហូតមកដល់ពេលនេះ។ ពួកគេនឹងដឹងពីផលប្រយោជន៍នៃការអនុវត្តអំពីអ្វីដែលពួកគេបានរៀនកន្លងមក យុវជនជាប្រជាជនអាចចេះនិយាយប្រឌិតអំពីពលកម្មកុមារ និងផលអាក្រក់ផ្សេងៗទៀត ដែលពួកយុវជនមានវ័យស្របាលគ្នា ក្នុងពិភពលោកនឹងយល់ពីអត្ថបទផ្សព្វផ្សាយរបស់ពួកគេ។ ពួកគេក៏អាចអភិវឌ្ឍព្រឹត្តិការណ៍ជាច្រើន ដើម្បីអំពាវនាវឱ្យមនុស្សពេញវ័យជួយនឹងប្រាប់អ្នកដទៃទៀតឱ្យចូលរួមក្នុងសកម្មភាពនេះតាមរយៈការផ្សាយព័ត៌មាន។ មេរៀននេះស៊ីសង្វាក់គ្នាល្អណាស់ជាមួយជំនាញផ្សេងៗទៀតដូចជា កែច្នៃសមត្ថភាពនិពន្ធ។ ជាការពិតសមត្ថភាពប៉ិនប្រសប់និពន្ធរបស់ពួកគេ នឹងជួយពួកគេក្នុងការពង្រាងអត្ថបទសារព័ត៌មាន និងការនិពន្ធទៅដល់អ្នកកាសែត និងអ្នករៀបរៀងអត្ថបទ។ វាគឺជាការពាក់ព័ន្ធដ៏កម្រដែលប្រជាជនជាយុវជនក្មេងៗត្រូវបានចាត់ឱ្យទទួលខុសត្រូវនៅពេលមានបញ្ហាដ៏សំខាន់នេះ។ មេរៀននេះ ក៏ផ្តល់ឱ្យពួកគេនូវឱកាសដ៏ថ្លៃថ្លាក្នុងការកត់សំគាល់របស់ពួកគេនៅក្នុងសហគមន៍។ ការងារធ្វើជាមួយព័ត៌មានផ្សព្វផ្សាយក្លាយទៅជាជំនាញដ៏ចាំបាច់ ក្នុងព័ត៌មានសេដ្ឋកិច្ចក៏ដូចជាសារព័ត៌មានទាំងឡាយ និងដំណើរផ្សេងៗពាក់ព័ន្ធលើផ្នែកសំខាន់ជាមួយនឹងជីវភាពរស់នៅរបស់ប្រជាជន។ ជំនាញនេះនឹងផ្តល់ឱ្យពួកគេយល់បានល្អផងដែរ នូវទេពកោសល្យដ៏ល្អសម្រាប់ការសិក្សានៅថ្ងៃមុខ ហើយធានាថាមេរៀនទាំងនោះដែលយុវវ័យក្មេងៗបាន រៀនពីវគ្គសិក្សាទាំងនេះនឹងស្ថិតនៅជាមួយពួកគេរហូតមួយជីវិត។

មេរៀននេះស៊ីជំរៅលើដំណើរការអភិវឌ្ឍផ្ទាល់ខ្លួន។ ការអនុវត្តសកម្មភាពនេះនឹងជួយអ្នកក្នុងការប៉ាន់ប្រមាណសក្តានុភាព ចរិតលក្ខណៈរបស់យុវជន ប្រជាជន ពេលអ្នកកំពុងបង្រៀនជាមួយពួកគេ វានឹងនាំមកនូវគុណសម្បត្តិយ៉ាងច្រើនក៏ដូចភាពជាអ្នកដឹកនាំការទំនាក់ទំនង និងភាពឈ្លាសវៃ។

# កិច្ចតែងការបង្រៀន



ព័ត៌មានថ្មីៗកំពុងកើតមានថ្ងៃនេះ អ្នកត្រូវប្រាប់ពីគំរោងរបស់ខ្លួនខណៈពេលដែលវាកំពុងកើតមាន មិនមែនទុកឱ្យវាកន្លងហួសជាច្រើនសប្ដាហ៍ក្រោយពេលវាបានបញ្ចប់នោះទេ។ នេះមានន័យថាក្នុងនាមជាអ្នកអប់រំ អ្នកត្រូវតែគិតអំពីពេលវេលា ដើម្បីអនុវត្តមេរៀននេះ។ ផែនការរបស់អ្នកត្រូវធ្វើដោយប្រុងប្រយ័ត្ន។

អ្នកនិងក្រុមពិភាក្សារបស់អ្នកនឹងត្រូវបង្កើតទំនាក់ទំនងជាមួយអ្នកសារព័ត៌មានក្នុងស្រុក និងអ្នករៀបរៀងអត្ថបទកាសែតមុននឹងដាក់អត្ថបទឱ្យពិនិត្យនៅកន្លែងផ្សាយព័ត៌មាន។ បញ្ហាអ្នករៀបរៀងច្បាស់ជាត្រូវបានជូនដំណឹងមុនថា អត្ថបទខ្លីរបស់អ្នកនឹងដល់កន្លែងផ្សាយពីរបីថ្ងៃបន្ទាប់ ហើយពួកគេច្បាស់ជាមានគំនិតមួយបញ្ជាក់ពីអ្វីដែលវានឹងបញ្ជាក់ឡើង។ ពួកគេច្បាស់ជាមានផែនការអំពីការបោះពុម្ពលើកក្រោយ ហើយដោយធ្វើការទំនាក់ទំនងជាមួយពួកគេមុន ហើយអ្នកនឹងដឹងថាគេចាប់ត្រៀមផ្សាយអត្ថបទជាបន្ទាន់ឬផ្ញើវានៅសប្ដាហ៍ផ្សេងទៀត នៅពេលដែលទំព័រកាសែតទំនេរពុំទាន់មានអត្ថបទចុះផ្សាយគ្រប់គ្រាន់។ វាមិនមែនជាគំនិតល្អទេ ដើម្បីសរសេរអត្ថបទហើយផ្ញើវាទៅកាន់កន្លែងបោះពុម្ពកាសែត ប្រសិនបើអ្នកដឹងច្បាស់ថាវានឹងមិនត្រូវបានចេញផ្សាយ បញ្ហានេះច្បាស់ជាធ្វើឱ្យក្រុមសរសេរបាក់ទឹកចិត្ត។ ការប្រើប្រាស់ពេលវេលាត្រឹមត្រូវគឺសំខាន់ណាស់។

អត្ថបទកាសែតខ្លះមានឥទ្ធិពលច្រើន បើសិនវាត្រូវបានរំលេចដោយរូបភាព ពេលអ្នកជំរាបទៅអ្នករៀបរៀង ឬអ្នកកាសែត អ្នកគួរស្នើសុំចុះផ្សាយដោយថតរូបភាពសកម្មភាពផ្សេងៗពេលឱកាសល្អហុចឱ្យជាឧទាហរណ៍ដូចជាទស្សនកិច្ចពេលខាងមុខដោយវាគ្មិនបញ្ចេញមតិ ឬក៏ជនល្បីៗ នៅពេលដែលមានការសំដែងជាល្ខោន ឬការដាក់តាំងពិពណ៌អំពីសិល្បៈសម្រាប់ប្រកួតប្រជែង និងវត្ថុផ្សេងៗ។ អ្នកត្រូវពិនិត្យឱ្យច្បាស់ថា អ្នកថតរូបមានពេលវេលា និងទីកន្លែងគ្រប់គ្រាន់សម្រាប់ថតរូបឱ្យបានហ្មត់ចត់។ ដូច្នេះគេចំណាយពេលវេលាសមល្មមដើម្បីនៅជិតកន្លែង សម្រាប់រូបថតរបស់ពួកគេ។ ជារឿយៗពួកគេរវល់មមាញឹកបំផុត និងជាអ្នកធ្វើការដោយសេរីលើផែនការ

កម្មវិធីដ៏តឹងរឹងបំផុតផងដែរ ។

ប្រសិនបើអ្នកមានសហសេវិកដែលមានបទពិសោធន៍ទាក់ទងនឹងការងារនៅជុំវិញអ្នក ហើយជាអ្នកស្ម័គ្រចិត្ត ដើម្បីធ្វើឱ្យគេមានលទ្ធភាពជួយអ្នកក្នុងការប្រតិបត្តិមេរៀននេះ អ្នកគួរតែប្រើប្រាស់ការជួយនេះឱ្យបានពេញលេញ ។ អ្នកប្រហែលជាស្គាល់នរណាម្នាក់ដោយផ្ទាល់ អ្នកនោះប្រហែលជាគ្រួសាររបស់យុវជន ប្រជាជនណាម្នាក់ដែលស្ថិតនៅក្រុមរបស់អ្នកនឹងជាអ្នកធ្វើការជាអ្នកមានបទពិសោធន៍នៅកន្លែងផ្សព្វផ្សាយ ។

គេអាចមានលទ្ធភាពធ្វើជាភ្នាក់ងារសារព័ត៌មាននៅក្នុងស្រុក អ្នកនឹងបញ្ជូនបុគ្គលិកណាម្នាក់មកជួយបង្ហាញមេរៀននេះ ។ ប្រសិនបើមិនមានទេពួកគេប្រហែលជាស្ម័គ្រចិត្តមកបង្ហាញដល់ក្រុមប្រជាជន អំពីភារកិច្ចជាអ្នកកាសែតម្នាក់ហើយនិងអំពីរបៀបសរសេរអត្ថបទរឿងមួយដែលត្រូវបានបោះពុម្ព ។ ជាធម្មតាប្រជាជនក្មេងៗគេចាប់អារម្មណ៍មែនទែន លើការងារផ្សព្វផ្សាយ ធ្វើដូចម្តេចក៏ដោយឱ្យតែមានអត្ថបទរបស់ពួកគេត្រូវបានផ្សាយនៅក្នុងទូរទស្សន៍ ឬវិទ្យុ ។ បន្ថែមលើលក្ខខ័ណ្ឌនេះ ការដកស្រង់ចម្រាញ់យកការគាំទ្ររបស់ស្ថានីយ៍ផ្សាយនៅថ្នាក់ជាតិ ឬស្ថានីយ៍ក្នុងស្រុកក៏ដោយក៏អ្នកគួរតែប្រុងប្រយ័ត្នលើកការងារអ្នកកំពុងធ្វើជាមួយក្រុមប្រជាជនក្មេងៗ ហើយត្រួសត្រាយរកវិធីសម្រាប់ការចេញផ្សាយអត្ថបទ ឬក៏ការសំភាសន៍តាមវិទ្យុ ឬទូរទស្សន៍នៅក្នុងស្រុក ម្យ៉ាងទៀតអ្នកគួរតែរកជំនួយរបស់ស្ថានីយ៍ផ្សាយ និងការទំនាក់ទំនងជាមួយជំនាញការ ឬក៏អ្នកឯកទេស ។ ប្រសិនបើអ្នកមិនអាចរកបានអ្នកគួរតែរកពួកគេនៅក្នុងបញ្ជីចុះលេខទូរស័ព្ទផ្ទាល់តែម្តង ។ ការផ្តល់ប្រធានបទមួយជាធម្មតាអ្នកគួរតែសុំកុំឱ្យពួកគេគិតថ្លៃសេវាផ្សព្វផ្សាយធ្វើអ្វី ។

## អ្វីដែលអ្នកត្រូវការ



- ✓ ក្រដាស ប៊ិច ឬ ខ្មៅដៃ
- ✓ ក្តារខៀនខ្មៅ ឬស ឬក្រដាសសផ្ទាំងធំ
- ✓ ប្រសិនបើទៅរួចគួរមានទូរស័ព្ទ ប៉ុន្តែនេះ
  មិនមែនមានន័យថាចាំបាច់ណាស់ណាទេ



## ការចាប់ផ្តើម



ការឈានចូលដល់ការអនុវត្តមេរៀននេះ អាស្រ័យលើកត្តាមួយចំនួនដូចជា :

- ថាតើអ្នកមានលទ្ធភាពអញ្ជើញ ឬមិនបានអញ្ជើញលោកវាគ្មិន ពីកន្លែងផ្សាយ ឬអត់ ។
- ថាតើអ្នកមានអ្នករួមការងារដទៃទៀត ឬបុគ្គលណាដែលនឹងជួយអ្នកដើម្បីបង្រៀនមេរៀនទាំងនេះ ។
- ថាតើអ្នកនឹងដឹកនាំបង្រៀនមេរៀននេះដោយខ្លួនឯងផ្ទាល់ ឬយ៉ាងណា ។

ទោះជាករណីនេះក៏ដោយ របៀបដោះស្រាយដូចបានពណ៌នាខាងក្រោមនេះ ជារបៀបដើម្បីជួយអ្នកឱ្យចេះអនុវត្តមេរៀនដោយខ្លួនឯងឱ្យបានគ្រប់គ្រាន់ដោយមិនចាំបាច់ត្រៀមរកអ្នកមានបទពិសោធន៍អ្វីទេ ។

## ការរៀបចំក្រុម



វិធីសាស្ត្រដែលមេរៀននេះនឹងដោះស្រាយបានដោយយថាហេតុ វាអាស្រ័យយ៉ាងមុតមាំលើក្រុមការងារ និង ចំណាប់អារម្មណ៍របស់ពួកគេ ។ នឹងមានការនិពន្ធមួយត្រូវបានដាក់រួមបញ្ចូលគ្នាក្នុងសារព័ត៌មាន ហើយកិច្ចការនេះ គឺជាការងារដ៏ល្អក្នុងការបែងចែកសិស្សជាក្រុមតូចៗ ដែលមានសមាជិកពី ២ ទៅ ៤ នាក់ ។ លំហាត់ទាំងនេះនឹងបង្កើតនូវជំនឿទុកចិត្តលើខ្លួនឯង ហើយពួកក្មេងទាំងនោះត្រូវការជំនឿនេះមុននឹងពួកគេឈានទៅទំនាក់ទំនងជាមួយនឹងកន្លែងផ្សាយ ។

ប្រសិនបើអ្នកកំពុងអនុវត្តមេរៀននេះ បន្ទាប់ពីមេរៀន "បង្កើនការនិពន្ធ"(ដែលត្រូវបានស្នើ) អ្នកគួរតែត្រូវរកឱ្យឃើញពាក្យពេចន៍បច្ចេកទេស ។ ត្រូវកំណត់ឱ្យច្បាស់ថាក្មេងៗទាំងនេះមិននៅក្នុងក្រុមដូចគ្នាទេ ប៉ុន្តែពួកគេត្រូវបានបំបែកជាក្រុមផ្សេងទៀត ដូច្នេះជំនាញពួកគេនឹងជួយគ្នាបាន ។ ពួកគេប្រហែលនឹងកាន់កាប់តួនាទី ដឹកនាំក្នុងអនុក្រុមរបស់ពួកគេ ដែលជាជំនួយសម្រាប់អ្នក ។

## ការរៀបចំឆាក

*ការបង្រៀនមួយពេល*

ទោះបីជាសព្វថ្ងៃព័ត៌មានបច្ចេកវិទ្យារីកចំរើនឆាប់រហ័សពេញពិភពលោកក៏ដោយ ក៏យើងមិនគួរមើលស្រាលឥទ្ធិពលការប្រើពាក្យពេចន៍សរសេរនោះទេ។ ការនិពន្ធល្អ និងសរសេរអត្ថន័យរិះគន់មានអត្ថបទល្អជាមួយសាច់រឿង គឺជាមធ្យោបាយមានប្រសិទ្ធភាពនៃការចេញផ្សាយជាសាធារណៈសម្រាប់គម្រោងរបស់អ្នក និងជាយុទ្ធនាការលុបបំបាត់ការកេងប្រវ័ញ្ចពលកម្មកុមារ។

ប្រសិនបើអ្នកបានទទួលជោគជ័យក្នុងការទាក់ទងវាគ្មិនម្នាក់ពីពិភពសារព័ត៌មាន នេះគឺជាចំនុចផ្តើមដ៏ល្អសម្រាប់ដំណើរការបង្រៀន។ អ្នកអញ្ជើញគាត់មកបកស្រាយដល់ក្រុមសិស្ស មុននឹងអ្នកចាប់ផ្តើមបញ្ចេញសកម្មភាពបង្រៀន អ្នកត្រូវមានការលើកទឹកចិត្តដល់ពួកគេពេលអ្នកសួរ និងឱ្យឆ្លើយនៅពេលអ្នកបានបង្រៀននៅចុងម៉ោង ទោះបីយ៉ាងណាក៏ដោយក្មេងៗប្រហែលជាមានអារម្មណ៍ស្ទាក់ស្ទើរ និងមានស្មារតីម្ចាស់ការលើការសាកសួរសំនួរ បើទុកជាពួកគេមានមនុស្សជាច្រើនសួររូបគេក៏ដោយ។ ដូច្នេះអ្នកត្រូវរៀបចំសភាពការណ៍នេះដោយសួរសំនួររបស់អ្នកផ្ទាល់។ ការធ្វើដូចនេះវានឹងលុបបំបាត់ភាពតប់ប្រមល់របស់ក្រុមសិស្សចេញ ហើយពួកគេនឹងមានជំនឿទុកចិត្តច្រើនលើការសួររបស់ពួកគេផ្ទាល់។ ចូរធ្វើឱ្យប្រាកដថាសំបុត្រអរគុណមួយច្បាប់ត្រូវបានផ្ញើឱ្យអ្នកវាគ្មិនបន្ទាប់ពីការចូលរួមទស្សនារបស់គាត់។ ថាជានិច្ចកាលការប្រឹងប្រែងនេះត្រូវបានពេញចិត្តយ៉ាងខ្លាំង ហើយវានឹងមានន័យពាក់ព័ន្ធនឹងការប្រឹងប្រែងរបស់បុគ្គលម្នាក់ៗនឹងបើកទូលាយនូវសំណើនៅថ្ងៃមុខដើម្បីការគាំទ្រ។

ប្រសិនបើអ្នកមិនអាចរកឃើញអ្នកវាគ្មិន ដើម្បីនិយាយទៅកាន់ក្រុមទេនោះ វាមានសារៈសំខាន់ណាស់សម្រាប់អ្នកពន្យល់ពួកក្រុមសិស្សឱ្យស្គាល់ពីរបៀបប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលពិភពលោកកំពុងដំណើរការសារព័ត៌មាននានា កាសែត សូម្បីកាសែតតូចៗនៅក្នុងស្រុកក៏មមាញឹកបំផុតក្នុងការរៀបចំផ្សាយ។ អ្នកយកព័ត៌មានរបស់ពួកគេគឺ ប្រៀបដូចជាអ្នករត់នៅ

លើដងផ្លូវស្ទើររាល់ថ្ងៃ ដើម្បីស្វែងរករឿងរ៉ាវព័ត៌មាននានា ការតាមដានរឿងរ៉ាវសំខាន់ៗ ដឹកនាំការសំភាសន៍ ការសម្របសម្រួលបណ្តាអ្នកប្រកួតប្រជែង និងអ្នកថតរូប ។ល។ បន្ទាប់មកពួកគេត្រូវចំណាយពេលវេលាទៅការិយាល័យ ដើម្បីយកអត្ថបទពួកគេទៅវាយបញ្ចូលក្នុងកុំព្យូទ័រ ឬក៏វាយបញ្ចូលទៅក្នុងកុំព្យូទ័រដោយខ្លួនឯង។ ពួកគេមានអត្ថបទដ៏ស្មុគស្មាញជាច្រើនស្ទើរយកជាការមិនកើត ដើម្បីបំពេញជារៀងរាល់សប្តាហ៍ ហើយពេលវេលារបស់ពួកគេគឺមានតម្លៃណាស់។ ដូចនេះវិធីដ៏ល្អដើម្បីទាញនូវការប្រុងប្រយ័ត្នរបស់ពួកគេ គឺអ្នកត្រូវជួយកិច្ចការរបស់ពួកគេឱ្យបានច្រើន និយាយបែបផ្សេងទៀត អ្នកត្រូវរៀបចំអត្ថបទបញ្ចេញមតិដែលពួកគេអាចផ្លាស់កន្លែងលើទំព័រកាសែត ទោះជាគេត្រូវការផ្លាស់ប្តូរ ឬក៏ពួកគេខ្វះពេលវេលា ដើម្បីធ្វើការតាមដានភ្លាមៗក៏ដោយ។

## សកម្មភាព ១ :

## ពង្រាងសារព័ត៌មានបញ្ចេញមតិបែបចំអកឡកឡឺយ

*ពេលបង្រៀនមួយមេរៀនពីរម៉ោង*

អ្នកចាប់ផ្តើមធ្វើការជាមួយក្រុមទាំងមូល។ អ្នកត្រូវសរសេរចំនុចសំខាន់ៗនៅលើក្តារខៀនជាបន្តបន្ទាប់ ប៉ុន្តែវាជាវិធីដ៏សំខាន់សម្រាប់ព្រាងអត្ថបទ។ អ្នកគ្រាន់តែសរសេរឃ្លាសំខាន់ៗ ហើយបកស្រាយពន្យល់មួយចំណុចម្តងៗនៅពេលដែលអ្នកបង្រៀន។

- **តើរឿងនោះជារឿងអ្វី?**

  ដើម្បីក្លាយជាព័ត៌មានដែលគួរឱ្យចង់អាននោះលុះត្រាតែអត្ថបទព័ត៌មានបកស្រាយពីសាច់រឿងដ៏ល្អមួយ។ វានឹងជួយអ្នកប្រសិនបើអ្នកអាចបង្កើតទិដ្ឋភាពប្លែកៗដ៏រស់រវើក រកមើលអ្វីជាប្រលោមលោកប្លែក ឬមានតែមួយគត់អំពីគម្រោងផែនការ។

- **និពន្ធឃ្លាខ្លីៗ ងាយស្រួលយល់**

  ការជក់ចិត្តនៃការផ្តោតអារម្មណ៍របស់អ្នកអានជាច្រើន អាស្រ័យលើរឿងវែង ខ្លី និងពិតជាក់ស្តែង ហើយឃ្លាវែង នៅក្នុងអត្ថបទអ្នកកុំឱ្យធុញទ្រាន់និងច្រឡំបល់។

- **សង្ខេបសាច់រឿង ឬឃ្លាប្រយោគឱ្យងាយយល់**

  ប្រាប់ពីសាច់រឿងនៅក្នុងប្រាំបន្ទាត់ដំបូង ឬក៏ផ្អែកលើវិធីបច្ចេកទេស ៥ W អ្នកណា? អ្វី? នៅពេលណា ? ទីណា? និង ហេតុអ្វី?



| | |
|---|---|
| អ្នកណា? | Who? |
| អ្វី? | What? |
| នៅពេលណា? | When? |
| ទីណា? | Where? |
| ហេតុអ្វី? | Why? |

- **បញ្ចូលពាក្យដកស្រង់សំខាន់ៗ**

  ពាក្យសំដីដែលដកស្រង់សំខាន់ៗធ្វើឱ្យអ្នកអានជក់ចិត្តចាប់អារម្មណ៍ ។ យកពាក្យគន្លឹះសំខាន់ៗរបស់បុគ្គលម្នាក់ៗមកបរិយាយអំពីអ្វីមួយ លំបាកធ្ងន់ធ្ងរ ដែលពាក់ព័ន្ធនឹងពលកម្មកុមារ ឬពាក់ព័ន្ធនឹងគម្រោងរបស់អ្នក ។ បើសិនជាអ្នកគ្មានពាក្យដកស្រង់ណាមួយនៅក្នុងដៃទេអ្នកត្រូវរកកត្តាជាក់ស្តែងខ្លះ ឬព័ត៌មានខ្លះបញ្ចូលទៅក្នុងអត្ថបទដកស្រង់សំខាន់ៗ និងពឹងពាក់នរណាម្នាក់ បើគេនឹងស្ម័គ្រចិត្តចូលរួមដកស្រង់យកសំដីរបស់ពួកគេ (ប៉ុន្តែត្រូវប្រុងប្រយ័ត្នអំពីការអនុវត្តនេះហើយកំណត់ឱ្យច្បាស់ថាបុគ្គលដែលយើងស្រង់យកសំដី ជានិច្ចកាលត្រូវបានយើងពិគ្រោះសុំយោបល់ហើយ ។



- **ត្រូវស្វែងរកចំណងជើងដែលគួរឱ្យចាប់អារម្មណ៍**

  ចំណងជើងសំខាន់ៗរបស់អ្នកគួរតែទាក់ទាញអារម្មណ៍ដល់អ្នកអាន ហើយជាផ្នែករិះគន់របស់អត្ថបទសារព័ត៌មានខ្លះ ។ ចំណងជើងតូចនៅចំនុចសំខាន់ៗជាយុទ្ធសាស្ត្រនៅក្នុងអត្ថបទសារព័ត៌មាននិងជួយបំបែកអត្ថបទដែលស្មុគ្រស្មាញឱ្យងាយយល់ ។

- **គួរជៀសវាងប្រើប្រាស់ពាក្យច្រូកច្របល់**

និងពាក្យជេរប្រមាថ អត្ថបទព័ត៌មានអ្នកគួរតែត្រូវបាន សរសេរឱ្យបានល្អ ហើយអត្ថបទមានដំណើរការមិនរដាក់រដុប។ ការប្រើប្រាស់ពាក្យលាយឡំគ្នា ឬពាក្យទីផ្សារអាចធ្វើឱ្យអ្នកអានគ្មានទឹកចិត្តអាន និងឈប់អានតែម្តង។

- **អត្ថបទគួរតែសរសេរឱ្យខ្លីបើអាចធ្វើទៅបាន**

ពិនិត្យឱ្យច្បាស់ថាអត្ថបទមានន័យច្បាស់ ខ្លី ហើយចំចំណុច។ គួរកាត់ចោលពាក្យណាដែលលើស ហើយផ្តោតអារម្មណ៍លើរឿងរ៉ាវដែលអ្នកចង់បាន។ អ្នករៀបរៀងខ្លះនឹងមិនពិនិត្យ មើលអត្ថបទណាដែលលើសពីមួយទំព័រទេ។ វាហាក់ដូចជាពិបាកបន្តិច ដើម្បីបំពេញអត្ថបទអ្នកចង់សរសេរលើក្រដាស់មួយទំព័រនេះ បានសេចក្តីថាអ្នកត្រូវតែប្រិតប្រៀងបំផុត នៅក្នុងរចនាបថ និងអត្ថបទអាទិភាពរបស់អ្នក។

- **ត្រូវប្រាប់ពួកគេថាអ្នកជានរណា**

នៅក្នុងទំព័រផ្នែកខាងលើអត្ថបទបញ្ចេញមតិសរសេរដាក់ជ្រុងខាងណាក៏បាន ឬលើក្របដើមទំព័រកំណត់ចំណាំ អ្នកគួរសរសេរដោយសង្ខេបពន្យល់ប្រាប់ថា អ្នក និងក្រុមរបស់អ្នកជានរណា។

- **ផ្តល់ឱ្យប្រព័ន្ធផ្សព្វផ្សាយនូវមធ្យោបាយងាយទាក់ទងជាមួយអ្នក**

វាមានសារសំខាន់ណាស់ដែល អាចងាយស្រួលស្គាល់ថាពួកគេជាអ្នកដែលគួរទាក់ទង ដើម្បីតាមដានព័ត៌មានលំអិតខ្លះនៅក្នុងអត្ថបទសារព័ត៌មានរៀបចំដាក់រូបថត។ល។ គ្រាន់តែផ្តល់ឱ្យពួកគេនូវការទាក់ទងសំខាន់មួយ ដូច្នោះពួកគេមិនត្រូវដេញឱ្យនៅឆ្ងាយពីមនុស្សម្នានៅជុំវិញខ្លួនគេទេ។ ពួកគេនឹងបាត់បង់ការអត់ធ្មត់យ៉ាងរហ័ស ហើយអ្នកនឹងបាត់បង់ឱកាស ដើម្បីឱ្យអត្ថបទរឿងរ៉ាវរបស់អ្នកចេញផ្សាយ ត្រូវអនុញ្ញាតឱ្យក្រុមសិស្សសួរសំណួរខ្លះៗពេលអ្នកពន្យល់បកស្រាយចំណុចទាំងនេះលើក្តារខៀន។ ពិនិត្យឱ្យច្បាស់ថាពួកគេបានយល់ពីចំណុចគន្លឹះនិងគោលការណ៍សំខាន់ៗនៃការសរសេរអត្ថបទព័ត៌មាន។ សួរសំណួរពួកគេផងដែរ ដើម្បីធានាឱ្យមានទំនុកចិត្ត លើខ្លួនអ្នកផ្ទាល់ថាពួកគេ

ពិតជាយល់ពីរបៀបសរសេរ។ អ្នកធ្វើការអះអាងឱ្យគេយល់ពីមេរៀនរបស់អ្នកដោយការលាយឡំសួរជាសំណួរ និងឱ្យឧទាហរណ៍ផង។

## ការកំណត់ភារកិច្ច



មែនហើយលំហាត់គឺចែកជាក្រុមតូចៗធ្វើការជាមួយគ្នាហើយបញ្ចេញមតិក្នុងអត្ថបទផ្ទាល់ខ្លួន។ គោលបំណងនេះគឺមិនចាំបាច់ផលិតអត្ថបទព័ត៌មានឱ្យចប់ជាស្ថាពរនៅតំណាក់កាលនេះ។ បញ្ហានេះវាពិតជាមិនល្អទេ មើលទៅគោលបំណងដំបូងនេះ ទោះបីជាក្រុមខ្លះអាចធ្វើទៅបានដែលអ្នកមិននឹកស្មានដល់។ គំនិតនេះគឺធ្វើឱ្យក្មេងៗ មានអារម្មណ៍ងាយស្រួលនឹងកិច្ចការសរសេរ ហើយចាប់ពីនោះមក អ្នកអាចរំកិល ការសរសេរអត្ថបទព័ត៌មានចុងក្រោយជាមួយគ្នា (មើលសកម្មភាពទី ២ខាងក្រោម)

ទោះបីយ៉ាងណាក៏ដោយមុននឹងបំបែកសិស្សជាក្រុមតូចៗ វិធីដ៏ល្អមួយ ដើម្បីឱ្យគ្រប់ៗគ្នាមានអារម្មណ៍ជ្រះស្រឡះ និងប្រកបដោយភាពច្នៃប្រឌិតនោះ គឺត្រូវចែះលៃពេលបំផុសគំនិតជាមួយនឹងវត្ថុបំណងឈានទៅរកនូវចំណងជើងដែលអត្ថបទព័ត៌មានប្រកបដោយអត្ថន័យល្អ។ អ្នករៀបរៀង ឬអ្នកកាសែតរហូតដល់អ្នកអានទាំងឡាយនឹងយល់ពីចំណងជើងយ៉ាងច្បាស់ ហើយធ្វើឱ្យពួកគេចង់អានតទៅទៀត បើសិនជាអ្នកបានរៀបចំព្រឹត្តិការណ៍មួយល្អ ឬក៏អ្វីមួយទៀតគ្រាន់តែយកមកជំនួសទោះចំណងជើងអត្ថបទត្រូវតែឆ្លុះបញ្ចាំងព្រឹត្តិការណ៍នោះក៏វាអាចត្រូវបានធ្វើជាគម្រោង ដើម្បីចេញផ្សាយទូទៅ។ ត្រូវឱ្យសមាជិកក្រុមទាំងអស់និយាយពីគំនិតអ្វីក៏ដោយ ឱ្យតែផុសចេញពីខួរក្បាលរបស់ពួកគេ។ ប្រាប់ឱ្យពួកគេបំផុសគំនិតដោយខ្លួនឯង។ សរសេរគំនិតផ្សេងៗរបស់ក្រុមនៅលើក្តារខៀនទោះ បីគំនិតនោះមានលក្ខណៈកំប្លែងមិនសមសម្យ ឬក៏មិនចំន័យសេចក្តីក៏ដោយ។ ជុំរុញលើកទឹកចិត្តពួកគេឱ្យមានភាពឆ្លាតវៃ និងកំប្លែង ឬក៏បង្ករលក្ខណៈឱ្យមានសំណើច ធ្វើឱ្យកំរើកប្រឌិតញាណ ហើយពួកគេនឹងមានឱកាសដ៏អស្ចារ្យរកឃើញនូវចំណងជើងដ៏ល្អៗ។ សម្រាកសកម្មភាពការងារចំនួនពី ៥ ទៅ ១០ នាទី។ បន្ទាប់មកឱ្យក្រុមសិស្សបោះឆ្នោតជ្រើសរើសយកចំណងជើងដ៏ល្អមួយ ហើយ

ត្រូវណែនាំពីចំណុចសំខាន់មួយនៃការប្រកួតផងដែរ ដោយរួមបញ្ចូលនូវរង្វាន់ ឬក៏រង្វាន់បីបួន។

នៅពេលដែលចំណងជើងមួយត្រូវបានសម្រេចយកអ្នកត្រូវសរសេរវា លើក្តារខៀន ហើយប្រាប់ក្រុមនីមួយៗឱ្យបង្កើតអត្ថបទព័ត៌មានដោយផ្អែក លើចំណងជើង។ រួចផ្តល់ឱ្យពួកគេនូវគោលការណ៍ណែនាំដូចខាងក្រោម ៖

- អត្ថបទបញ្ចេញមតិមិនគួរឱ្យលើសពី ២៥០ ពាក្យ ហើយគួរសរសេរ ប្រហែលជាពាក់កណ្តាលក្រដាសមានទំហំ A4 ។
- ប្រយោគផ្តើមមិនត្រូវឱ្យលើសពី ៥ បន្ទាត់ ដែលរួមបញ្ចូលចំណុច សំខាន់នៃអត្ថបទដោយប្រើប្រាស់វិធី សាស្រ្ត ៥W ។
- នៅក្នុងអត្ថបទគួរតែមានចំណងជើងតូចមួយយ៉ាងតិច។
- គួរតែមានពាក្យសំដីដកស្រង់មួយយ៉ាងតិចនៅក្នុងអត្ថបទ ពាក្យសំដី នោះបានមកពីអ្នកអប់រំឧទាហរណ៍ចេញពីអ្នក ឬក៏ពីនរណាម្នាក់នៅ ក្នុងក្រុម។
- វាច្បាស់ជាមានរឿងមួយទាក់ទងនឹងអត្ថបទ វាមិនមែនគ្រាន់តែរៀប រាប់ពីហេតុការណ៍ភ្ជាប់គ្នាដោយពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងៗ ដែលរាក់កំផែលនោះទេ។

ត្រូវផ្តល់ឱ្យក្រុមទាំងអស់នូវពេលវេលាយ៉ាងច្រើនពី ៣០ ទៅ ៤០ នាទី ដើម្បីតាក់តែងអត្ថបទព័ត៌មាននោះជាការគ្រប់គ្រាន់។ ពិនិត្យឱ្យជាក់ ច្បាស់ថាក្រុមនីមួយៗកំពុងដំណើរការបានល្អ ទោះបីជាមានកាត់តចុះឡើងក្នុង ចំណោមក្រុមទាំងអស់ក៏ដោយ។ អ្នកត្រូវអង្គុយជាមួយក្រុមរយៈពេលខ្លី ប្រសិនបើអ្នកយល់ឃើញថា ពួកគេកំពុងមានបញ្ហា ឬកំពុងគិតយ៉ាងលំបាក។ អ្នកបង្កើតយោបល់បន្តិចបន្តួចបានដូចទៅនឹងអ្វីដែលប្រហែលនឹងបញ្ចូលទៅ ក្នុងអត្ថបទបញ្ចេញមតិ។ ខណៈពេលដែលពួកគេបានធ្វើការចាប់ផ្តើម ហើយ ចំណុចផ្សេងៗនឹងមានជាបន្តបន្ទាប់។ ជាធម្មតា ១ ឃ្លា ២ ឃ្លាដំបូងវាពិបាក បំផុត។ ជំរុញពួកគេឱ្យប្រើវិធីសាស្រ្ត ៥W នោះវានឹងជួយជំរុញពួកគេឱ្យធ្វើ

លំហាត់សរសេរដោយងាយស្រួល ដោយការជំរុញពួកគេឱ្យឆ្លើយនូវសំណួរបាន។

ប្រសិនបើអ្នកអាចលាតត្រដាងអ្នកនិពន្ធជាក់លាក់ខ្លះ ក្នុងចំណោមក្រុមសិស្ស អ្នកមិនគួរមានបញ្ហាច្រើនជាមួយលំហាត់ទេ។ ២៥០ ពាក្យ គឺមិនច្រើនទេ ហើយក្មេងៗស្ទើរតែទាំងអស់នឹងលៃលកសរសេរបាន។ ធ្វើឱ្យពួកគេមានទំនុកចិត្តថា អ្នកមិនត្រូវការយកគុណភាពនៅដំណាក់កាលនោះទេ។ វត្ថុបំណងចំបងគឺឱ្យក្រុមនីមួយៗ សរសេរពីអ្វីមួយ ហើយបង្ហាញថាពួកគេអាចសរសេរបានដោយផ្ទាល់ខ្លួន។ ព្យាយាមពិនិត្យថា សមាជិកម្នាក់ៗក្នុងក្រុមតូចៗកំពុងបញ្ចេញមតិ ហើយពិនិត្យថា មិនមែនតែបុគ្គលម្នាក់ទេដែលធ្វើលំហាត់ ព្រៀងទាំងអស់តែម្នាក់ឯងបាននោះ។ ស្ថិតនៅក្នុងកំឡុងពេលវេលាកំណត់របស់អ្នកត្រូវពិនិត្យថាក្រុមនីមួយៗបានបំពេញកិច្ចការទាន់ពេលឬទេ។ មិនត្រូវដំអក់ពេល ឱ្យការពង្រាងនេះយឺតពេកទេ។ អ្នកគួរហៅពួកគេឱ្យឈប់ធ្វើកិច្ចការនៅពេលជិតដល់ម៉ោងបញ្ចប់ ទោះបីគ្មាននរណាម្នាក់បានបញ្ចប់វាក៏ដោយ។ ឱ្យក្រុមទាំងអស់ជ្រើសតាំងអ្នកតំណាងក្រុម ដើម្បីអានអត្ថបទព័ត៌មានរបស់ពួកគេ។ ប្រសិនបើអ្នកដឹងថាមានចំណុចសំខាន់មួយជែងគ្នានោះ នឹងបន្ថែមភាពភ្ញាក់ផ្អើលបន្តិចហើយមានការចាប់អារម្មណ៍ពីបណ្ដាក្រុម អ្នកអាចផ្តល់ជារង្វាន់មួយចំពោះសន្លឹកកិច្ចការណាដែលបញ្ចប់បានល្អបំផុត។



អត្ថបទបន្ថែម១គឺជាអត្ថបទដែលសរសេរដោយក្មេងស្រីពីរនាក់ដែលបានចូលរួមប្រលងសាកល្បងនៃបណ្ដាម៉ូឌុលទាំងនេះ នៅឯសាធារណៈរដ្ឋអៀរឡង់ ក្នុងឆ្នាំ ២០០១ ។ អត្ថបទនេះបានបោះពុម្ពនៅឯរោងពុម្ពព័ត៌មានតាមតំបន់ ហើយអត្ថបទនេះប្រហែលជួយអ្នក និងក្រុមរបស់អ្នកក្នុងការធ្វើលំហាត់នេះ។ វាគឺជាអត្ថបទមានលក្ខណៈបែបពិពណ៌នាជាងអត្ថបទបញ្ចេញមតិ ប៉ុន្តែវាជាការងារផ្ទាល់របស់ពួកគេ ហើយកិច្ចការរបស់ក្រុមទាំងអស់មានឥទ្ធិពលច្រើនដោយសារវា។

# សកម្មភាព ២

## សេចក្តីព្រាងសារព័ត៌មាន

*បង្រៀនពីរពេលជាប់គ្នា*

ផ្នែកទី២នៃលំហាត់នេះគឺបង្កើតអត្ថបទមតិជាមួយក្រុមទាំងមូល ក្នុងវត្ថុបំណងឱ្យមានការបោះពុម្ពវាក្នុងទម្រង់នៃប្រព័ន្ធផ្សព្វផ្សាយស្នាដៃ។ ការត្រួសត្រាយផ្លូវដឹកនាំសកម្មភាព។

## ការត្រួសត្រាយផ្លូវ




មុននឹងឈានទៅដល់កិច្ចការចុងក្រោយនៃការអភិវឌ្ឍអត្ថបទមួយសម្រាប់បោះពុម្ព អ្នកគួរធ្វើការជាមួយក្រុម លើផ្នែកទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយនៅក្នុងស្រុក ដើម្បីកំណត់ដោយអត្ថបទ។ អ្នកជ្រើសរើសកាសែតក្នុងស្រុកជាច្រើន នឹងត្រូវមានគោលបំណងឱ្យអត្ថបទនេះចេញផ្សាយលើទំព័រកាសែតជាតិ ឬទស្សនាវដ្តីផ្សេងៗក្នុងការបញ្ចេញមតិ។ ទោះយ៉ាងណាក៏ដោយ ដើម្បីផលប្រយោជន៍ក្នុងក្រុមរបស់អ្នក និងដើម្បីឱ្យមានការទុកចិត្តរបស់ពួកគេ អ្នកត្រូវចាប់ផ្តើមជាមួយនឹងកាសែតក្នុងស្រុកមួយ ឬពីរដោយមានសំណាងល្អ អត្ថបទរបស់អ្នកនឹងត្រូវបានចេញផ្សាយក្នុងស្រុក។

នេះជាការសំខាន់ ដើម្បីឱ្យមានការគាំទ្រពីខាងក្រៅ (មើលផ្នែកខាងលើ)។ ការទាក់ទងខ្លះនឹងលើកតម្លៃអត្ថបទព័ត៌មានបានបោះពុម្ពផ្សាយស័ក្តិ-សមល្មមសម្រាប់ធ្វើការប្រើប្រាស់។ ទាក់ទិនជាមួយក្រុមសិស្ស ទំនាក់ទំនងជាមួយអ្នករៀបរៀង ឬអ្នកកាសែត។ ចូរអ្នកឱ្យពួកគេជ្រើសរើសអ្នកតំណាងដើម្បីធ្វើការទាក់ទង និងបង្កើតការប្រជុំជាសង្ខេបខ្លឹមសារខ្លះៗ ជាមួយក្រុមទាំងអស់អំពីអ្វីដែលអ្នកតំណាង គួរនិយាយអំពីអត្ថបទព័ត៌មានដែលនឹងចេញផ្សាយ ។ស្វែងរកពេលវេលាល្អដើម្បីទាក់ទងជាមួយអ្នករៀបរៀងជាឧទាហរណ៍ មានកាសែតក្នុងស្រុកខ្លះ គឺចេញផ្សាយមួយអាទិត្យម្តង ដូចនេះវាគ្មានប្រយោជន៍ទេ បើព្យាយាមហៅអ្នករៀបរៀងផ្ទៀងផ្ទាត់នៅមុនពេលថ្ងៃដែលកាសែតចេញផ្សាយ។ ការចេញផ្សាយគួរតែធ្វើឡើងនៅថ្ងៃបោះពុម្ពហើយ

ឬក៏បន្ទាប់ពីការបោះពុម្ព គឺនៅពេលដែលការងារផ្សេងៗត្រូវបានបញ្ចប់នៅក្នុងការិយាល័យ ។

រឿងរ៉ាវសំខាន់ត្រូវបានបញ្ជាក់នោះ គឺដើម្បីស្ទង់អំពីចំណាប់អារម្មណ៍របស់អ្នករៀបរៀងក្នុងការបោះពុម្ព អត្ថបទរបស់ក្រុមការងារដែលបានធ្វើហើយ នឹងអ្វីជាពេលកំណត់សម្រាប់អត្ថបទសារព័ត៌មានបន្ថែមពីលើនេះ អ្នកផ្សេងផ្ទាត់គួរត្រូវបានសួរថា តើរូបថតមួយណាគួរមានសារប្រយោជន៍ ដើម្បីដាក់រំលេចក្នុងអត្ថបទ ហើយសំណើផ្សេងៗ ត្រូវធ្វើឡើងដោយក្រុមការងារសម្រាប់រូបថតដែលថតដោយអ្នកថតរូបសារព័ត៌មាន ។ អ្នករៀបរៀងអាចផ្តល់ចំណុចដៅសមស្របជាក់លាក់ អាស្រ័យលើថេរវេលានៃអត្ថបទ ។

## ការផ្សព្វផ្សាយព័ត៌មានចុងក្រោយ



ជាទូទៅការបញ្ចេញមតិលើទំព័រសារព័ត៌មានគួរតែមានចំនួន ៥០០ ពាក្យ (យ៉ាងហោចណាស់ក៏អ្នក បានឮតាមរយៈអ្នកនិពន្ធសារព័ត៌មានដែរ) ។ ប្រសិនបើមានលទ្ធភាព ការសរសេរ សមាសភាគអត្ថបទកាសែត ឱ្យសរសេរខ្លីងាយយល់ គឺជាការប្រសើរ ។

វាពិតជាអាចធ្វើទៅបានការបញ្ចេញមតិលើទំព័រសារព័ត៌មាននឹងមានភាពវិសេសវិសាល ដែលនឹងធ្វើឱ្យកិច្ចការក្រោយៗទៀតមានភាពងាយស្រួលជាងមុន ។ ការងារបន្ទាប់របស់អ្នក គឺជាការទិះទៀនកែលំអ ដើម្បីឱ្យបានប្រសើរ នៅក្នុងដំណាក់កាលក្រោយ ប្រកបដោយប្រសិទ្ធភាព អ្នកត្រូវចូលរួមបញ្ចេញព័ត៌មានខ្លីៗ ហើយនិពន្ធខ្លឹមសារទាំងនោះឱ្យទៅជាអត្ថបទដ៏វែងមួយ ។ អ្នកត្រូវតែស្តាប់ដោយប្រុងប្រយ័ត្នបំផុតរាល់អត្ថបទទាំងឡាយណាដែលខុសពីគ្នា ហើយត្រូវកត់ត្រានូវចំណុចល្អនានាដាក់ជាក្រុមដទៃពីគ្នា ។ អ្នកត្រូវតែវែកញែកអត្ថបទទាំងនោះ អំពីអ្វីជាអាទិភាពរបស់អ្នកក្នុងការបញ្ចេញមតិសារព័ត៌មាន :

តើមានចំណុចអ្វីខ្លះ ជាចំណុចចម្បងដែលអ្នកចង់បានតាមរយៈអ្នកអាន?

ផ្អែកលើមូលដ្ឋាននេះ អ្នកអាចកាត់តដើម្បីចាប់ផ្តើមរកអត្ថបទរួមគ្នាមួយ ក្នុងការតែងនិពន្ធអត្ថបទសារព័ត៌មានជាចុងក្រោយមួយ ។ វាចៀសមិនរួចទេដែលអ្នកត្រូវធ្វើការបំពេញ និងតាក់តែងកិច្ចការខ្លះ ដើម្បីភ្ជាប់បែបបទ និងឃ្លាប្រយោគខុសៗគ្នា ។ កិច្ចការខ្លះអាចត្រូវធ្វើឡើងបានដោយសរសេរលើក្តារខៀន លើក្រដាសផ្ទាំងធំ ឬក៏ពឹងនរណាម្នាក់ឱ្យសរសេរជាអត្ថបទថ្មី ។ មធ្យោបាយល្អ និងសាមញ្ញបំផុត គឺធ្វើការកាត់ និងតភ្ជាប់ បន្ទាប់មកពិនិត្យមើលកន្លែងឃ្លាណាដែលនៅខ្វះចន្លោះ រួចត្រូវសរសេរកែសម្រួលកន្លែងដែលកាត់តនោះតាមសេចក្តីត្រូវការ ។ បន្ទាប់មកត្រូវផ្តុំគ្នាជាក្រុមឡើងវិញ ដើម្បីដំណើរការសរសេរ និងបង្កឱ្យក្រុមមានភាពសោមនស្សរីករាយ ។

នៅពេលដែលអត្ថបទមួយត្រូវបានអភិវឌ្ឍហើយអត្ថបទនោះនឹងត្រូវបានសម្រិតសម្រាំងសម្រេចបានលទ្ធផលល្អវិសេស ។ ក្រោយពីទទួលបានអត្ថ-បទ ហើយក្រុមសិស្សត្រូវចាប់អភិវឌ្ឍឃ្លាប្រយោគដោយផ្អែកលើវិធីសាស្ត្រ ៥W (ហេតុអ្វី? ដូចម្តេច? នៅពេលណា? នៅទីណា? អ្នកណា?) ។

ចុងបញ្ចប់ឱ្យប្រកាន់យកព័ត៌មានសង្ខេបសំខាន់ៗដទៃទៀត ។ ព័ត៌មានសង្ខេបសំខាន់ៗនោះ គឺជាមាតិកានៃអត្ថបទសារព័ត៌មានដ៏ល្អ ដែលក្រុមសិស្សសម្រេចចិត្តយកដែរ ឬទេ? ឥឡូវនេះអត្ថបទសារព័ត៌មានទាំងមូលត្រូវបានរៀបចំរួចជាស្រេច រួចអានអត្ថបទនោះម្តងទៀតទៅកាន់សមាជិកក្រុម ហើយសួរថា តើមានគំនិតដទៃទៀតត្រូវបន្ថែមដែរឬទេ ដើម្បីឱ្យអត្ថបទសារព័ត៌មានកាន់តែសុក្រឹត ។ តាមការពិតការផ្តល់គំនិតខុសៗគ្នានឹងធ្វើឱ្យអត្ថបទថ្មីមានន័យទូលំទូលាយ ។ ពេលនេះអ្នកគួរតែឱ្យអ្នកស្ម័គ្រចិត្តនិពន្ធអត្ថបទសារព័ត៌មានចុងក្រោយសរសេរឱ្យមានរបៀបរៀបរយ ឬក៏ឱ្យគេវាយកុំព្យូទ័រ បើសិនជាអាចបាន អ្នកគួរផ្តល់ថាស ដើម្បីថតអត្ថបទនោះរក្សាទុក ឬមួយបោះពុម្ពថតទុកជាឯកសារសម្រាប់អ្នក ។ បានសរសេរអត្ថបទចប់ហើយ អ្នកត្រូវឱ្យក្រុមសិស្សទាំងមូល ទៅទាក់ទងជាមួយសារព័ត៌មានក្នុងស្រុក ដើម្បីផ្ញើអត្ថបទទៅកាន់កន្លែងអនុញ្ញាតចេញផ្សាយ ហើយពិនិត្យមើលលើការព្រមព្រៀងដែលត្រូវធ្វើសម្រាប់ថតរូប ។ អត្ថបទសារព័ត៌មានផ្សេងទៀត ត្រូវតាមដានឱ្យជាប់ដោយទូរស័ព្ទទៅកាន់អ្នកកាសែត ឬអ្នកបោះពុម្ពផ្សាយ ដើម្បី

បញ្ជាក់ច្បាស់ថា តើអត្ថបទនឹងត្រូវបានបោះពុម្ព ឬអត់។

### កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

វាមានសារៈសំខាន់ណាស់ ដើម្បីកំណត់ពេលសម្រាប់ប្រតិបត្តិផ្សព្វផ្សាយសារព័ត៌មានរបស់អ្នក។ ប្រសិនបើសាខាសហជីពសារព័ត៌មានរបស់អ្នកត្រូវការអត្ថបទព័ត៌មាននៅថ្ងៃច័ន្ទ ម៉ោង ១២ ថ្ងៃត្រង់ ដូចនេះអត្ថបទព័ត៌មាននោះនឹងត្រូវចេញជួយលើទំព័រកាសែតនៅថ្ងៃសុក្រ ទោះអ្វីៗត្រូវបានកើតមានឡើងដោយពិតប្រាកដ។ អ្នកយកអត្ថបទបញ្ចេញមតិទៅឱ្យមន្ត្រីពិនិត្យឱ្យបានត្រឹមត្រូវតាមពេលកំណត់។ អ្នកគួរលៃពេលណា គឺជាពេលកំណត់ ហើយពេលណាអ្នកត្រូវនិយាយ ទូរស័ព្ទទៅកាន់ការិយាល័យសារព័ត៌មាន។

ស្នាក់ការសារព័ត៌មានជាច្រើនកន្លែងទទួលអត្ថបទនិពន្ធរាប់រយពីប្រភពផ្សេងៗ ក្នុងវគ្គសិក្សាសម្រាប់មួយសប្តាហ៍។ អ្នកត្រូវតែកំណត់ឱ្យច្បាស់ថាអត្ថបទរបស់អ្នកនឹងត្រូវបានប្រើប្រាស់ ឬអត់ដែលតម្រូវឱ្យអ្នកតាមដានតាមទូរស័ព្ទ ដោយធ្វើការងារជាមួយអ្នកតំណាងក្រុមដទៃទៀត គឺលើកឡើងពីសកម្មភាពសរសេរនេះ។



នៅឧបសម្ព័ន្ធទី២ គឺជាសារព័ត៌មានបានបោះពុម្ពផ្សាយក្នុងកំឡុងពេលធ្វើតេស្តសាកល្បងម៉ូឌុលនេះក្នុងសាធារណៈរដ្ឋអៀកឡង់។ ដើម្បីមានអនុភាពដល់ក្រុមនិពន្ធរបស់អ្នកនូវគំនិតទាំងឡាយ ដែលជំរុញទឹកចិត្តគេឱ្យខិតខំអភិវឌ្ឍផ្ទាល់ខ្លួនថែមទៀត។

### កំណត់សម្គាល់សម្រាប់អ្នកប្រើប្រាស់

វត្ថុបំណងនៃមធ្យោបាយផ្សព្វផ្សាយអត្ថបទសារព័ត៌មាន គឺសម្រាប់ក្រុមអ្នកសរសេរ និងបានបោះពុម្ពតាមបែបបទរបស់កាសែតក្នុងស្រុក។ បើសិនជាអត្ថបទត្រូវបានបោះពុម្ព ការធ្វើការងារជាក្រុម ដើម្បីសរសេរសំបុត្រថ្លែងអំណរគុណចំពោះអ្នកបោះពុម្ព ហើយត្រូវផ្ញើសំបុត្រនោះទៅភ្លាមតាមតែការដែលអាចធ្វើទៅបាន បន្ទាប់ពីអត្ថបទលើទំព័រកាសែតបានចេញផ្សាយ។ បន្ទាប់មកទៀតអ្នកត្រូវមានការលើកទឹកចិត្តដល់ក្រុមការងារឱ្យទូរស័ព្ទទៅកាន់អ្នកបោះពុម្ព ឬក៏អ្នកកាសែតដែលពាក់ព័ន្ធ ដើម្បីថ្លែងអំណរគុណពួកគេទាំងនោះដោយផ្ទាល់ខ្លួន ហើយសួរពួកគេអំពីព័ត៌មានដែលត្រូវតាមដាន ឬក៏រឿងរ៉ាវផ្សេងទៀត ពិសេសនឹងត្រូវរក្សាទុកនូវរឿងរ៉ាវស្តីពីពលកម្មកុមារនៅលើទំព័រកាសែតតទៅទៀត។

ក្នុងវគ្គសិក្សាអ្នកត្រូវប្រាប់ឱ្យដឹងមុនអំពីការយល់ដឹងសមាគមន៍ អត្ថបទកាសែតក្នុងស្រុកនៅក្នុងសាជីវកម្មសារព័ត៌មាន គឺជិតឈានទៅដល់ស្នាដៃកំពូលដែលមានរាយនាមក្នុងបញ្ជីអ្នកមានស្នាដៃ។ អ្នកដឹកនាំក្រុមសិស្សឱ្យកាត់អត្ថបទទំព័រកាសែត និងចាប់ផ្ដើមរៀបចំដាក់ដោយឡែកនៅកន្លែងរក្សាទុកអត្ថបទព័ត៌មាន។ បើសិនជាអត្ថបទមិនបានត្រូវបោះពុម្ព អ្នកកុំអស់សង្ឃឹមហើយត្រូវបញ្ជាក់ឱ្យច្បាស់ ដើម្បីកុំឱ្យក្រុមការងារបាក់ទឹកចិត្ត។ អ្នកគាំទ្រពួកគេក្នុងការទាក់ទងជាមួយអ្នកបោះពុម្ព ឬអ្នកកាសែតដែលមានការពាក់ព័ន្ធ ត្រូវហ៊ានសួរនាំពីមូលហេតុដែលអត្ថបទព័ត៌មានមិនបានចេញផ្សាយ។ នេះគឺជាកិច្ចការដ៏មានសារប្រយោជន៍ណាស់ ដើម្បីបញ្ជាក់ពីការមិនបានចេញផ្សាយសារព័ត៌មានរបស់ក្រុមអ្នក ឧទាហរណ៍ដូចជាគ្មានចន្លោះគ្រប់គ្រាន់សម្រាប់ចេញផ្សាយនៅសប្ដាហ៍នេះ។ ដូច្នេះអត្ថបទរបស់អ្នកប្រហែលចេញផ្សាយនៅសប្ដាហ៍ក្រោយ។ ឆ្លងតាមរយៈការសួរនាំពីមូលហេតុមិនបានចេញផ្សាយអត្ថបទរបស់អ្នក ក្រុមការងារនឹងអាចស្វែងយល់ពីអ្វីដែលអាចកែប្រែអត្ថបទក្រោយៗឱ្យកាន់តែល្អប្រសើរជាងមុន។ វាគឺជាមេរៀនបទពិសោធន៍សម្រាប់ពួកសិស្ស និងសម្រាប់អ្នក ហើយវាក៏ផ្ដល់នូវការលើកទឹកចិត្តដល់ក្រុមការងារផងដែរ កំណត់ឱ្យជាក់លាក់ថា រឿងរ៉ាវមួយត្រូវបានបោះពុម្ពផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយអំពីពលកម្មកុមាររួចបង្ខិតបង្ខំពួកគេឱ្យបញ្ឈប់អំពើពុំគប្បីទាំងនោះ។

## អ្វីដែលត្រូវធ្វើ និងមិនត្រូវធ្វើ

- អ្នកពិនិត្យឱ្យច្បាស់លាស់ថាសិស្សគ្រប់ៗគ្នាបានចូលរួមគ្រប់មេរៀននៃវគ្គសិក្សានេះ។
- អ្នកធ្វើឱ្យប្រាកដថាក្រុមនីមួយៗសរសេរអំពីរឿងរ៉ាវអ្វីមួយ វាមិនមានបញ្ហាអ្វីទេដែលថាអត្ថបទសរសេររបស់សិស្សខ្លីប៉ុណ្ណាឬក៏អត្ថន័យលំអិតច្របូកច្របល់យ៉ាងណានោះទេ។
- អ្នកត្រូវប្រើអារម្មណ៍ និងការនិយាយលេងសើចដោយចិត្តស្មោះត្រង់ជាមួយក្រុមសិស្ស ដើម្បីជួយឱ្យវគ្គសិក្សាបន្តទៅបានយូរ។ ជាឧទាហរណ៍ការបន្ទូរអារម្មណ៍ពិតជាអាចជួយក្នុងការអភិវឌ្ឍន៍ខ្លឹមសារបានល្អ។





- អ្នកត្រូវជំរុញលើកទឹកចិត្តក្រុមការងារទាំងនោះឱ្យអានអត្ថបទសារព័ត៌មានរបស់ពួកគេ ។
- មិនត្រូវអនុញ្ញាតឱ្យក្រុមការងារលេងសើចនៅពេលសរសេរអត្ថបទនីមួយៗនោះទេ ។
- ការសរសើរលើកទឹកចិត្តក្រុមទាំងនោះលើស្នាដៃការងាររបស់ពួកគេ ។ អ្នកប្រាប់ពួកគេថា ការខិតខំប្រឹងប្រែងរបស់ពួកគេនឹងមានតម្លៃក្នុងការចេញអត្ថបទសារព័ត៌មានជាចុងក្រោយសម្រាប់សាខាសារព័ត៌មាននៅក្នុងស្រុក ។
- អ្នកត្រូវរក្សាទុករាល់អត្ថបទសារព័ត៌មានក្រុមទាំងនោះ បានសរសេររួចហើយឱ្យបានគង់វង្ស ។

## ការពិភាក្សាបញ្ចប់

*បង្រៀនមួយពេល*

ដោយមានការពិភាក្សាចុងក្រោយរបស់អ្នកបន្ទាប់ពីអត្ថបទសារព័ត៌មាន ត្រូវបានបំពេញដោយការពេញចិត្តរបស់អ្នក និងក្រុមសិស្សរបស់អ្នក ។ កិច្ចធ្វើការងារជាមួយប្រព័ន្ធផ្សព្វផ្សាយ គឺជាទស្សនីយភាពដ៏គួររំភើបចិត្តមួយ ហើយក្រុមសិស្សរបស់អ្នកប្រហែលជានឹងឆ្លើយតបបានល្អនឹងវគ្គសិក្សានេះ ។ ពួកគេនឹងស្រឡាញ់គំនិតរបស់អ្នកនិពន្ធលើទំព័រកាសែត និងមានប្រជាជនក្នុងសហគមន៍របស់ពួកគេចូលចិត្តអានអំពីអ្វីមួយដែលពួកគេកំពុងរៀន និងកំពុងធ្វើ ។ ពួកគេនឹងចូលចិត្តផងដែរដោយបានឃើញរូបថតរបស់ពួកគេនៅលើទំព័រកាសែត ។ ពួកគេនឹងបារម្ភបន្តិចដែរដោយនិយាយថា ពួកគេមើលទៅអាក្រក់គួរឱ្យខ្លាច ហើយពួកគេគ្មានសង្ឃឹមថានរណាម្នាក់បានស្គាល់រូបថតពួកគេនៅលើទំព័រកាសែតឡើយ ។ ក៏ប៉ុន្តែតាមការពិតពួកគេរីករាយយ៉ាងជ្រាលជ្រៅ និងមានមោទនភាពយ៉ាងខ្លាំងនូវអ្វីដែលពួកគេគួរធ្វើ ។ អ្នកត្រូវអនុញ្ញាតឱ្យពួកគេបន្ធូរបរិយាកាសខ្លះៗ នៅពេលពួកគេបំពេញកិច្ចការនឿយហត់ ។

អ្នកជួយលើកកំពស់ស្មារតី និងការចាប់អារម្មណ៍ក្នុងក្រុមដោយសកម្មភាពរស់រវើកក្នុងការផ្ដល់មតិជាចុងក្រោយ ។ អ្នកត្រូវប្រាប់ពួកគេទាំងអស់គ្នា

ឱ្យតាមដានការបោះពុម្ពជាបន្តបន្ទាប់របស់កាសែតក្នុងស្រុក ដើម្បីឱ្យដឹងថា អត្ថបទរបស់ពួកគេត្រូវបានបោះពុម្ព។ វានឹងទៅជារឿងអ្វីមួយដែលត្រូវរង់ចាំ ហើយវានឹងផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនសម្រាប់អនុវត្តការបោះពុម្ពនោះ។ ជាឧទាហរណ៏អ្នកបោះពុម្ពប្រហែលជាយកចិត្តទុកដាក់ផ្ទាល់ខ្លួនលើកិច្ចការ និង គំរោងផែនការ ដែលអ្នកកំពុងដឹកនាំ។ អ្នកកាសែតប្រហែលជានឹងយកអស់ កំលាំងកាយចិត្ត ចេញផ្សាយអត្ថបទកាសែតសម្រាប់រយៈពេលពីរសប្តាហ៏។ អ្នកគួរផ្តល់យោបល់ថា ពួកគេប្រហែលជាយកចិត្តទុកដាក់ក្នុងការបោះពុម្ព ផ្សាយពីរឿងខ្លីៗរបស់ក្រុមការងារ ឬក៏ទម្រង់រចនារូបភាពដទៃទៀតដែល ក្រុមរបស់ពួកគេ បានផលិតដូចជារូបភាព និងរូបគំនូរ។



## ការវាយតំលៃ និងសកម្មភាពបន្ត

ក្នុងល័ក្ខខ័ណ្ឌដែលអាចវាស់នឹងចំណុចដៅបានរបស់អត្ថបទមេរៀននេះ ពិតជាមានទិន្នផលជាក់លាក់ គឺអាចវាស់បានក្នុងនោះពួកគេបានចាប់អារម្មណ៍ ឬក៏មិនបានចាប់អារម្មណ៍។ ក្រុមសិស្សតូចៗនឹងបានផលិតអត្ថបទសារព័ត៌មានខ្លីៗ ដោយផ្អែកលើកិច្ចការរបស់ពួកគេនោះ ថ្នាក់ទាំងមូលនឹងផលិតបានអត្ថបទសារព័ត៌មានយ៉ាងវែងមួយ។ ចំណុចដៅសំខាន់ៗបន្ថែមទៀតរួមមាន :



- ធ្វើការទាក់ទងរៀបចំជាមួយទីកន្លែងប្រព័ន្ធផ្សព្វផ្សាយ (ឬក្នុងតំបន់ ឬនៅថ្នាក់ជាតិ) សរសេរផ្សាយព័ត៌មាន។
- អត្ថបទបញ្ចេញមតិសារព័ត៌មានត្រូវបានបញ្ជូនផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ។
- កាសែតមួយច្បាប់បានបោះពុម្ពផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយដោយផ្អែកលើមូលដ្ឋានអត្ថបទនិពន្ធ។
- សកម្មភាពធ្វើបន្តទាំងឡាយបានរៀបចំក្នុងហេតុផលជាបន្តបន្ទាប់ក្នុងការបោះពុម្ពផ្សាយ។

ម៉ូឌុលនេះកំពុងប្តូរទិសដៅរកដំណាក់កាលទាក់ទងសកម្មភាពចូលរួមជាសាកលក្នុងយុទ្ធនាការ ដើម្បីលុបបំបាត់ពលកម្មលើកុមារ។ ហេតុដូចនេះចំណុចដៅបង្ហាញទាំងឡាយខាងលើ មានសារសំខាន់ណាស់ក្នុងការកំណត់នូវអ្វីជាវិសាលភាពនិពន្ធរបស់ក្រុម ដែលត្រូវចំណាយពេលវេលាក្នុងការធ្វើសកម្មភាពគួរឱ្យចាប់អារម្មណ៍ និងការចូលរួមរបស់ពួកគេក្នុងផែនការ និងការផ្សព្វផ្សាយ។ លទ្ធផលនៃសកម្មភាពនេះ នឹងមានសារសំខាន់សម្រាប់អ្នកអប់រំក្នុងការវាយតម្លៃផ្ទាល់ខ្លួន និងការអនុវត្តមេរៀននេះ ដើម្បីកំណត់ការចូលរួមរបស់ក្រុមសិស្ស និងបុគ្គលម្នាក់ៗនៅក្នុងក្រុមសិក្សា។

មេរៀនដ៏ពិសេសនេះ គឺជាគន្លឹះសម្រាប់ការបង្រៀនក្រុមសិស្សក្មេងរបស់អ្នក។ រាល់សកម្មភាពក្នុងវគ្គសិក្សានេះ បង្ហាញពួកគេពីរបៀបដែលពួកគេអាចទទួលយក ដើម្បីផ្សព្វផ្សាយពីហេតុការណ៍ថ្មីៗនៃបញ្ហាពលកម្មកុមារ។

ពួកគេអាចបង្ហាញពីអារម្មណ៍របស់ពួកគេនៅទូទាំងសហគមន៍ធំៗ ហើយមាននរណាម្នាក់ដឹងថា សារជាអក្សរបានចេញពីកន្លែងណានោះ។ ក្រុមសិស្សឯទៀត និងបុគ្គលទាំងនោះប្រហែលជាចេះអភិវឌ្ឍន៍ចំណាប់អារម្មណ៍ និងបង្កើតទំនាក់ទំនង។ អាជ្ញាធរអប់រំតាមមូលដ្ឋានប្រហែលជាចាប់អារម្មណ៍លើអ្វីដែលយុវជនក្មេងៗកំពុងធ្វើ។ ការទទួលសារជាអក្សរបញ្ចូលទៅក្នុងប្រព័ន្ធផ្សព្វផ្សាយអាចចាប់ផ្តើមបើកច្រកទ្វារជាច្រើន ដែលអ្នកមិនធ្លាប់ដឹងសោះ។

មេរៀននេះបញ្ជាក់ពីសារលិខិតនៃសេចក្តីសង្ឃឹមក្នុងក្រុម។ ពួកគេយល់ឃើញថាមិនមែនអ្វីៗគឺសុទ្ធតែអស់សង្ឃឹមទេ ហើយមានវិធីជាច្រើននឹងមានតម្លៃចំពោះពួកគេ ដើម្បីទទួលយកការងារជាវិជ្ជមាន។ វាអាចមានឥទ្ធិពលខ្លាំងប្រសិនបើបានចាត់ចែង និងដឹកនាំដោយស្មោះត្រង់។ ក្នុងករណីអត្ថបទព័ត៌មានបានចេញផ្សាយអ្នកត្រូវកំណត់ឱ្យច្បាស់ថា អ្នកមានមោទនភាពអភិវឌ្ឍ និងជឿជាក់ហើយការលើកទឹកចិត្តពួកសិស្សទាំងនោះដោយទទួលយកកិច្ចការធ្វើបន្ថែមទៀត។

ខណៈពេលគ្រូបានបញ្ចប់វគ្គសិក្សានេះ អ្នកនឹងមានសេចក្តីពេញចិត្ត យើងផ្តល់ជាអនុសាសន៍ថានៅវគ្គសិក្សាក្រោយៗទៀត អ្នកពិតជាអនុវត្តជាក់ស្តែងដោយនាំក្រុមសិស្សទៅកាន់តំបន់ផ្សេងៗទៀត ដែលមានយុទ្ធនាការផ្សព្វផ្សាយ (មើលប្រព័ន្ធផ្សព្វផ្សាយ វិទ្យុ និងទូរទស្សន៍) អត្ថបទសរសេរដែលអ្នកបានអភិវឌ្ឍ ដែលជាសារៈប្រយោជន៍ក្នុងការទំនាក់ទំនងឈានមុខជាមួយប្រព័ន្ធផ្សព្វផ្សាយទាំងនេះ។

# ឧបសម្ព័ន្ធ ១

## អត្ថបទនេះផ្សព្វផ្សាយនៅក្រុង Scariff New ប្រទេសអៀរឡង់ ក្នុងខែ មីនា ឆ្នាំ ២០០១។

## ពលកម្មកុមារ

**ដោយ អង់កាក់ណែត កុឈីន (១៦) និង ដេនី ចុលតុន (១៦)**

អ្នកប្រហែលជាបានដឹងរួចមកហើយនូវទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារដែលយើងជានិស្សិតបានបញ្ចប់បានចូលរួមនៅឯ Scariff Community College ។ កិច្ចការនេះបានក្លាយជាគំរោងព័ត៌មានសំខាន់ក្រៃលែង។ ពួកយើងបានខិតខំស្វែងរកជាខ្លាំងសម្បើម អំពីអំពើដ៏ឃោរឃៅអមនុស្សធម៌នៃពលកម្មកុមារ ហើយនិងបញ្ហាថាហេតុអ្វីបានជាមានកុមាររត់ចេញទៅរកការងារធ្វើនៅខាងក្រៅ។

នៅពេលចាប់ផ្តើមគំរោងរបស់ពួកយើង លើកំណត់ត្រាមិនផ្លូវការ ពួកយើងទាំងអស់គ្នាបានយកផ្នែកខ្លះនៃកាសែត និងទស្សនាវដ្តីចាស់ៗ បង្កើតបានជាប្រភេទរូបភាពពីរខុសៗគ្នា។ រូបភាពទី១គឺជាព័ត៌មានដែលយើងបានជ្រើសរើស រីឯរូបភាពទីពីរគឺជាប្រធានបទពលកម្មកុមារ។ នៅពេលថ្មីៗនេះយើងបានតាំងបង្ហាញរូបភាពពលកម្មកុមារនៅក្នុងថ្នាក់រៀនរបស់ពួកយើង។ យើងបានសិក្សាពីរ ឬបីពេលក្នុងមួយសប្តាហ៍ អំពីគំរោងការពលកម្មកុមារ។ ក្នុងកំឡុងពេលសិក្សាមេរៀនទាំងនេះ យើងពិភាក្សាអំពីរូបភាព និងកត្តាអ្វីខ្លះដែលបណ្តាលឱ្យមានពលកម្មកុមារ។ ពេលសិក្សាមេរៀនថ្នាក់របស់ពួកយើងខ្លះបានថតជាវីដេអូ ហើយនៅពេលថតចំលងវីដេអូនេះនឹងត្រូវបានលើកជាគំរោងពិនិត្យ និងផលិតវីដេអូជាក្រោយ។

កំឡុងពេលម្តងក្នុងមួយសប្តាហ៍ ក្នុងម៉ោងរៀនភាសាអង់គ្លេសរបស់ពួកយើងយើងទទួលបានកាសែតជាច្រើន ហើយពួកយើងពិនិត្យអត្ថបទកាសែតទាំងនោះ សម្រាប់ទុកជាអត្ថបទចាប់អារម្មណ៍របស់ពួកយើង។ ចំណែកគ្រូដទៃទៀតកំពុងទាក់ទងចូលរួមធ្វើគំរោងជាមួយពួកយើងដែរ។ ក្នុងថ្នាក់ខ្លះពេលកំពុងរៀន យើងបានពិភាក្សាអំពីប្រធានបទជាច្រើនដែលទាក់ទងនឹងគំរោងដូចជានៅក្នុងភូមិវិទ្យា ដែលយើងកំពុងសិក្សាពីមូលហេតុដែលនាំឱ្យមានភាពក្រីក្រ។

ទិដ្ឋភាពដទៃទៀតរបស់គំរោងពួកយើង ដែលពួកយើងកំពុងតែជក់ចិត្តសប្បាយយ៉ាងក្រៃលែងនោះ គឺម៉ោងរៀនហាត់ល្ខោន។ មេរៀនទាំងនេះគឺមិនដូចមេរៀនផ្សេងៗទៀតដែលយើងបានរៀនពីមុនទេ។ យើងកំពុងរៀបចំរឿងល្ខោនមួយ សម្រាប់ពួកយុវជនឱ្យសំដែងនៅថ្ងៃបុណ្យរំលឹកខួបការបង្កើតសិល្បៈល្ខោននាថ្ងៃទី ១៥ ខែ មីនា។

នៅថ្ងៃទី១៤ ខែ កុម្ភៈ យើងបានបើកអង្គប្រជុំពិភាក្សាគ្នាអំពីរឿងល្ខោនរំជួលចិត្តមួយ ៖ កុមារទាំងឡាយ ត្រូវតែទៅសាលារៀនមិនមែនទៅធ្វើការងារទេ។ រឿងនេះបានបង្ហាញពីអត្ថន័យដែលទស្សនិកជនពុំដែលជួបប្រទះ។ ក្រុមប្រឹក្សាជាន់ខ្ពស់ម្នាក់ឈ្មោះ Clare បានចូលរួមប្រជុំពិភាក្សា ហើយបានប្រាប់ពួកយើងពីវិធី

ដែលធ្វើឱ្យគាត់ចាប់ចិត្តយ៉ាងខ្លាំងលើការរៀបចំអត្ថន័យរឿងរបស់ពួកយើង។ ពួកយើងក៏មានអ្នកចូលរួមម្នាក់ទៀតមកពីសមាជិកសភាតំណាងរាស្ត្រ ដែលបានចាប់អារម្មណ៍លើគម្រោងរបស់ពួកយើងយ៉ាងខ្លាំង។ និស្សិតខ្លះទៀតក៏បានសំភាសន៍ ជាមួយអ្នកនយោបាយទាំងពីរនេះដែរ។

ចាប់ពីថ្ងៃទី ១៥ ដល់ ខែ កុម្ភៈ យើងមានសោមនស្សរីករាយដោយបានចូលរួមសិក្ខាសាលា ស្តីពីការនិពន្ធអំពីស្នាដៃអ្នកនិពន្ធ Larry O’Louglin ។ Larry បានសរសេរសៀវភៅដែលមានចំណងជើងថា " តើនរណាខ្លះកំពុងស្តាប់?" ដែលផ្សារភ្ជាប់នឹងបញ្ហាពលកម្មកុមារ។ គ្រប់ៗគ្នាសប្បាយរីករាយនឹងការពិភាក្សាយ៉ាងហ្មត់ចត់អំពីស្នាដៃរបស់គាត់នៃរឿង "តើនរណាកំពុងស្តាប់" គម្រោងរបស់ពួកយើង គឺនិយាយពីមនុស្សវ័យក្មេងទាំងឡាយ និងអ្វីដែលពួកយើងអាចធ្វើ ដើម្បីជួយលុបបំបាត់ការកេងប្រវ័ញ្ចលើកំលាំងពលកម្មកុមារនៅជុំវិញពិភពលោក។ ដោយទទួលបានយល់ដឹងយ៉ាងច្រើនអំពីបញ្ហាទាំងឡាយ និងការយល់ដឹងពីហេតុផលនៃពលកម្មកុមារដែលកើតមានពិតនោះពួកយើងមានអារម្មណ៍ថា យើងអាចចូលរួមក្នុងការសំដែងអ្វីមួយអំពីបញ្ហាទាំងនេះ។

មុនពេលអ្នកអាចធ្វើអ្វីមួយបាននោះ អ្នកត្រូវការយល់ដឹងបន្ថែមឱ្យបានច្រើន។ ប៉ុន្តែខណៈអ្នកយល់ដឹងឱ្យបានច្រើនពេលនេះ វាមិនអាចមានលទ្ធភាពទៅរួច ដែលនាំគ្នាអង្គុយជុំវិញ ដោយមិនធ្វើអ្វីមួយសោះនោះទេ។

ការប្រើប្រាស់ជំនាញដែលយើងបានរៀន យើងជឿជាក់ថាយើងអាចធ្វើអ្វីមួយមានភាពខុសគ្នា។ នេះគឺជាអ្វីដែលវត្ថុបំណងរបស់គម្រោងរបស់យើងបានធ្វើឡើង ដើម្បីកែប្រែភាពខុសគ្នាមួយក្នុងជីវិតរាប់លាននាក់របស់ការងារកុមារនៅជុំវិញពិភពលោក។

# ឧបសម្ព័ន្ធ ២

ក្រុមសរសេរអត្ថបទសារព័ត៌មានក្នុងប្រទេសអៀរឡង់កាលពីខែមករាឆ្នាំ ២០០១ការកេងប្រវ័ញ្ចផ្លូវភេទសម្រាប់សិស្សនៅ Scariff ក្រុមសិស្សវ័យក្មេងមួយក្រុមមកពីសាកលវិទ្យា Scariff កំពុងឈានមុនគេលើគំរោងដ៏ធំ មួយដែលអាចជួយលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មកុមារនៅពាសពេញពិភពលោក។ សិស្ស ២៤ នាក់ ក្នុងការឆ្លងកាត់សិក្សាឆ្នាំបញ្ចប់នៅឯវិទ្យាល័យ Clare ខាងកើតកំពុងចូលរួមចំណែកក្នុងការអភិវឌ្ឍកម្មវិធីសាកល្បង ដកពិសោធន៏នៃវត្ថុបំណងបង្កើនការយល់ដឹងក្នុងចំណោមយុវជនវ័យក្មេងជុំវិញបញ្ហាពលកម្មកុមារ។

ដោយបានមើលការខុសត្រូវពីអង្គការពលកម្មអន្តរជាតិ (ILO) នៅទីក្រុងហ្សឺណែវ (Geneva) ក្នុងប្រទេសស្វីសនោះគំរោងស្នើឡើងត្រូវបានចាប់ផ្តើមអភិវឌ្ឍដោយកម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ការកេងប្រវ័ញ្ចពលកម្មកុមារ (IPEC) ។ ពួកគេបានប្រគល់មុខងារឱ្យលោក Nick Grisewood ដែលជាអ្នកទំនាក់ទំនងជាមួយទីប្រឹក្សានៅឯ Scariff ដើម្បីបង្កើតមេរៀនអប់រំមួយក្បាល ដែលអាចប្រើប្រាស់នៅក្នុងសាលារៀននានាជុំវិញពិភពលោក។ Nick មានទំនុកចិត្តថា ការធ្វើការជាមួយសាលារៀន គឺជាមាគ៌ាល្អឥតខ្ចោះដើម្បីដោះស្រាយបញ្ហាពលកម្មកុមារ "មាគ៌ាដ៏ល្អបំផុត ដើម្បីបង្កើតរូបភាពខុសៗគ្នាយូរអង្វែងឆ្ពោះទៅរកស្ថានភាពនៃពលកម្មកុមារ នៅជុំវិញពិភពលោក គឺតាមរយៈការអប់រំពិសេសការអប់រំយុវជនក្មេងៗ" ។

ដំណាក់កាលសាកល្បងលើគម្រោងស្នើឡើងនេះ គឺត្រូវបានអនុវត្តក្នុងកិច្ចសហប្រតិបត្តិការយ៉ាងជិតដិតជាមួយបុគ្គលិកសិក្សានៅឯមហាវិទ្យាល័យ Scariff Community ។ "នេះគឺជាឱកាសដ៏ល្អប្រពៃណីសម្រាប់និស្សិតក្រុមយើង ដើម្បីធ្វើការក្នុងបរិបទធំមួយហើយពួកគេមានអារម្មណ៍ថា ពួកគេកំពុងកែប្រែរូបភាពខុសគ្នាមួយ។ នេះគឺជាការគិតថា សាលាតូចមួយដ៏អស្ចារ្យនេះ ដូចជាសាលារៀនរបស់ពួកយើងនៅឯជនបទក្នុងប្រទេសអៀរឡង់ ដែលអាចដើរតួសំខាន់ក្នុងការនាំមកនូវមូលដ្ឋានគោលការណ៏ផ្លាស់ប្តូរសំខាន់ៗ នៅពាសពេញពិភពលោក " នេះជាសំដីរបស់លោក IJ Mason នាយកមហាវិទ្យាល័យ Scariff Community".

ទិដ្ឋភាពផ្លាស់ប្តូរថ្មីមួយនៃគម្រោងស្នើឡើងនេះ គឺវាគ្របដណ្តប់គ្រប់ផ្នែកនៃកម្មវិធីសិក្សា ដូចជានៅ Geral dine Condren អ្នកសម្របសម្រួលវគ្គសិក្សាឆ្នាំបញ្ចប់បានបកស្រាយពន្យល់ ។ បណ្តានិស្សិតទាំងនោះកំពុងតែមើលឃើញអំពីពលកម្មកុមារ ដែលបានមកពីគ្រប់ទិសទី ពួកគេកំពុងធ្វើប័ណ្ណរូបភាពក្នុងថ្នាក់រៀនហាត់សិល្បៈ កំពុងសិក្សាទិដ្ឋភាពក្រីក្រក្នុងផែនទីភូមិវិទ្យា ការស្រាវជ្រាវអំពីទំនាក់ទំនងរវាងអក្សរសាស្ត្រ និងកំណាព្យក្នុងថ្នាក់រៀនសាភាអង់គ្លេស និងភាសាអៀរឡង់ ហើយពួកគេបានខិតខំរៀបចំការប្រជុំពិភាក្សាដោះស្រាយជុំវិញទិដ្ឋភាពពលកម្មកុមារ ដោយនិស្សិតឆ្នាំទី៥ និងនិស្សិតឆ្នាំបញ្ចប់ ។

គម្រោងដែលស្នើឡើងរួមបញ្ចូលទាំងការទំនាក់ទំនងដ៏ធ្ងន់ធ្ងរលើការសំដែងល្ខោនតូរ្យតន្ត្រី និងការបង្កើតស្នាដៃនិពន្ធ។ សិស្សទាំងអស់កំពុងធ្វើការជាមួយនឹងអ្នកដឹកនាំល្ខោនក្នុងស្រុក ដើម្បីអភិវឌ្ឍន៍ និងសំដែងរឿងល្ខោនមួយរឿង ដែលនឹងត្រូវបានចូលរួមសំដែងក្នុងថ្ងៃបុណ្យ East Clare Drama ឆ្នាំនេះ។

ប្រតិកម្មមកវិញនៃគម្រោងស្នើឡើងនេះ គឺបានលទ្ធផលជាវិជ្ជមាននៅពាសពេញផ្ទៃសហគមន៍ទាំងមូល បណ្ណាល័យ Clare County បានជួយពិនិត្យ និងឧបត្ថម្ភដោយផ្តល់ការបណ្តុះបណ្តាលតាមអ៊ីនធឺណែត Internet និងសិទ្ធិប្រើប្រាស់ដល់ពួកនិស្សិតឱ្យជក់ចិត្តនឹងផលធនធានមានតម្លៃសម្រាប់ស្រាវជ្រាវនៅក្នុងបណ្ណាល័យនានា នាទីក្រុង Kilaloe និង Scrariff ។

ការផ្លាស់ប្តូរខ្លះក្នុងវិស័យពលកម្មកុមារពាសពេញពិភពលោកនឹងត្រូវបានដាក់ឱ្យពិនិត្យជាកំហិតនៅក្នុងឆាកនយោបាយ ហើយនិស្សិតឆ្នាំបញ្ចប់បានបង្ហាញទិដ្ឋភាពនេះ ដោយការអញ្ជើញចូលរួមពីលោក Tony Killeen T.D និងសមាជិកក្រុមប្រឹក្សាជាន់ខ្ពស់គឺ Paul Bugler ដើម្បីទស្សនាមហាវិទ្យាល័យ Scariff Community ហើយពិនិត្យមើលស្នាដៃដំបូងដែលបាននិពន្ធ។ ដូចជាមានសារៈសំខាន់អ្វី១ អញ្ជើងដែលអ្នកនយោបាយទាំងពីរនាក់បានសន្យាធ្វើអ្វីមួយដល់ពួកគេអាចធ្វើបាននៅតាមថ្នាក់ជាតិ និងនៅតាមមូដ្ឋាន ដើម្បីបង្កើនភាពអស្ចារ្យនៃទិដ្ឋភាពនេះ។

លោក Frans Roselaers នាយក IPEC នៅហ្សឺណែវ បាននិយាយថា ឆន្ទៈ និងសេចក្តីត្រេកអររបស់ក្រុមនិស្សិត គឺជាការជុំរុញលើកទឹកចិត្តដ៏ល្អបំផុតសម្រាប់ក្រុមមន្ត្រីការងារ IPEC នៅទីក្រុងហ្សឺណែវ និងនៅជុំវិញពិភពលោក។

យើងជឿជាក់ថា មនុស្សពេញវ័យទាំងឡាយអាចចូលរួមនាំមុខគេក្នុងចលនាសង្គម នៅពេលដែលការស្រមើស្រមៃ និងការប្រឹងប្រែងញាណរបស់ពួកគេ ត្រូវផ្តល់ការរាំងខ្ទប់ដោយសេរី។ ហេតុដូច្នេះអ្នកអប់រំទាំងឡាយនឹងផ្តល់ការអនុញ្ញាតឱ្យនិយាយដល់សមត្ថភាពយុវវ័យ ដើម្បីសន្មតជាមុននូវទំនួលខុសត្រូវក្នុងការកសាងវប្បធម៌សិទ្ធិមនុស្ស ។

ជោគជ័យនៃគម្រោងថ្មីក្នុងវគ្គសិក្សាដ៏វែងមួយនៅឯ Scariff Community College នឹងនៅជារបៀបដ៏ស័ក្តសិទ្ធិមួយ ដែលនិស្សិត Clare ខាងកើតអាចមានការយល់ដឹងប្រកបដោយប្រសិទ្ធភាព។ និស្សិតឆ្នាំបញ្ចប់ឈ្មោះ Nollaig Burke ពន្យល់ថា វាគឺត្រូវបានប៉ាន់ស្មានថាមានកុមារអាយុក្រោម ១៨ ឆ្នាំ ជាង ២៤៩ លាននាក់ កំពុងធ្វើការនៅជុំវិញពិភពលោក។ ក្នុងចំណោមក្មេងទាំងអស់នោះមានក្មេងប្រហែល ១៧៩ លាននាក់កំពុងធ្វើការក្នុងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។ គម្រោងស្នើរបស់ពួកយើងនឹងត្រូវបានប្រជាជននៅលើសកលលោកកំពុងជួយបង្រៀនឱ្យមនុស្សវ័យក្មេងផ្សេងៗទៀតយល់អំពីសោកនាដកម្មនៃការកេងប្រវ័ញ្ចពលកម្មកុមារ។ ជាមួយនឹងចំណេះដឹងនោះខ្ញុំសង្ឃឹមថា ពួកកុមារទាំងឡាយ និងពួកយើងជានិស្សិតអាចកែច្នៃភាពខុសគ្នា

ក្នុងរយៈពេលដ៏យូរអង្វែងមួយ។ អង្គការពលកម្មអន្តរជាតិ IPEC ត្រូវបានចាប់ផ្តើមនៅឆ្នាំ ១៩៩២ ដើម្បីជួយប្រទេសដែលកំពុងប្រយុទ្ធនឹងពលកម្មកុមារ តាមរយៈកម្មវិធីសកម្មភាពទាំងឡាយការស្រាវជ្រាវការអភិវឌ្ឍនយោបាយ ហើយនឹងការគាំទ្រ។ អង្គការពលកម្មអន្តរជាតិ IPEC ឥឡូវនេះកំពុងធ្វើប្រតិបត្តិការ ក្នុង ៧៤ ប្រទេសគ្រប់ភូមិភាគលើពិភពលោក។

## គណៈកម្មការដឹកនាំ និងគ្រប់គ្រង

| | |
|---|---|
| ១_លោក ភុង ហានស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២_លោក តួច ជឿន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក គួច គួលំអ | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤_លោក ចាប គឹមជុន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក ណុប ទឹម | ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

## គណៈកម្មការរៀបរៀង និងចងក្រង

| | |
|---|---|
| ១_លោក ភុង ហានស៊ីន | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២_លោក តួច ជឿន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក គួច គួលំអ | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤_លោក ចាប គឹមជុន | អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក ណុប ទឹម | ជំនួយការនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៦_លោក ឡង់ សុផាត | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

## គណៈកម្មការបកប្រែ

| | | | |
|---|---|---|---|
| ១_លោកស្រី កង សុថាវី | ប្រធានការិយាល័យក្រោយអក្ខរកម្ម | ២_លោកស្រី តុប ប៊ុនថា | ប្រធានការិយាល័យអក្ខរកម្ម |
| ៣_លោក ញ៉ែម ភីណារ៉េត | អនុប្រធានការិយាល័យរដ្ឋបាល | ៤_លោក តេះ ដារី | អនុប្រធានការិ.ផែនការនិងគ្រប់គ្រងទិន្នន័យ |
| ៥_លោក ជិន និវត្តន៍ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៦_លោកស្រី ទី វត្តី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៧_លោក ភូ យន់ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៨_លោកស្រី ស្រ៊ុន ម៉ាទី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៩_កញ្ញា អ៊ុក ធារី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ១០_លោក គ្រួច លក្ខិណា | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ១១_លោកស្រី លី ខេង | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | | |

## គណៈកម្មការផ្ទៀងផ្ទាត់

| | | | |
|---|---|---|---|
| ១_លោក សំ ចាន់ទិត | អនុប្រធានការិយាល័យអក្ខរកម្ម | ២_លោក រង់ សូវង្ស | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣_លោក ឈុំ ច័ន្ទមុនីរ៉េត | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៤_លោកស្រី ជា សុផល | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៥_លោក កែវ គង់ | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | ៦_កញ្ញា ម៉ៅ ផល្លី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៧_លោកស្រី ស្រ៊ុន ម៉ាទី | មន្ត្រីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | | |

## គណៈកម្មការឌីហ្សាញ និងកុំព្យូទ័រ

| | |
|---|---|
| ១_លោក ឈិន វ៉ិត | ប្រធានការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ២_លោក ពេជ្រ និពន្ធ | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៣_លោកស្រី ឈុំ សោភ័ណ | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៤_លោកស្រី សួច ផាន់ណា | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៥_លោកស្រី ទី រ៉ាដា | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |
| ៦_កញ្ញា សន សុម៉ាលី | មន្ត្រីការិយាល័យផែនការ គ្រប់គ្រងទិន្នន័យព័ត៌មាន |

# ✕ បញ្ឈប់ពលកម្មកុមារ

## Stop Child Labour

**Supporting Children's Rights through Education, the Arts and the Media (SCREAM)**

**សូមថ្លែងអំណរគុណ**

- ដល់អង្គការពលកម្មអន្តរជាតិ (ILO) ដែលបានជួយឧបត្ថម្ភថវិកា ក្នុងការបកប្រែ រៀបរៀង និងបោះពុម្ព។
- ចំពោះលោក **មេនណាធីរ ប៉ូល យ៉ូសេហ្វ** ប្រធានទីប្រឹក្សាបច្ចេកទេស និងលោក **ថេង ឆវីរិទ្ធ** មន្រ្តីកម្មវិធីនៃ *អង្គការពលកម្មអន្តរជាតិ* (ILO) កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC) គាំទ្រកម្មវិធីពេលវេលាកំណត់ (TBP SP) នៅកម្ពុជាដែលបានជួយផ្តល់ការណែនាំផ្សេងៗ និងការគាំទ្របច្ចេកទេស ព្រមទាំងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងនេះ ដើម្បី **ស្រ្គីម** (SCREAM) កើតមានឡើងនៅកម្ពុជា។

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ យុវជន និងកីឡា តាមសេចក្តីប្រកាស លេខ 101 អយក ប្រក ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៦

នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ : លេខ ១៦៨ មហាវិថីព្រះនរោត្តម សង្កាត់បឹងកេងកង១ ខណ្ឌ ចំការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : **(០២៣) ៧២៦ ៥៦៣ / ២១៩ ២៥៨**

**Email** : **nfe@camnet.com.kh**

ISBN- 9789995088217